# Child Care Suspension Resources for Families (ធនធានទាក់ទងនឹងការព្យួរអាជ្ញាបណ្ណថែទាំកុមារសម្រាប់គ្រួសារ)

### សំណួរ៖ តើអ្វីជាការផ្តល់អាជ្ញាបណ្ណថែទាំកុមាររបស់ DCYF?

**ចម្លើយ៖** Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ, DCYF) ផ្តល់អាជ្ញាបណ្ណប្រហែល 6,000 ដល់មណ្ឌលលក្ខណ:គ្រួសារ មណ្ឌលថែទាំកុមារ កម្មវិធីសម្រាប់កុមារដែលមានអាយុចូលរៀន និងកម្មវិធីផ្អែកលើធម្មជាតិខាងក្រៅនៅក្នុងរដ្ឋ Washington។ អ្នកផ្តល់សេវាថែទាំកុមារដែលមានអាជ្ញាបណ្ណអនុវត្តតាមស្តង់ដារគុណភាពមូលដ្ឋានគ្រឹះ គឺ Washington Administrative Code (ក្រមរដ្ឋបាលរដ្ឋ Washington, WAC) ដែលកំណត់ដោយរដ្ឋ ដើម្បីធានាថាកុមារដែលនៅក្នុងកន្លែងថែទាំដែលមានអាជ្ញាបណ្ណស្ថិតនៅក្នុងបរិយាកាសដែលមានសុវត្ថិភាព ផ្តល់សុខភាពល្អ និងមានការទំនុកបម្រុង។

### សំណួរ៖ តើអ្វីជាការព្យួរអាជ្ញាបណ្ណ?

**ចម្លើយ៖** វាជាចំណាត់ការភ្លាមៗដែល DCYF ប្រើដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាព។ ការថែទាំកុមារមិនអាចដំណើរការបានទេក្នុងអំឡុងពេលព្យួរអាជ្ញាបណ្ណ។ "ព្យួរ" នៅពេលប្រើសំដៅលើស្ថានភាពផ្តល់អាជ្ញាបណ្ណអ្នកផ្តល់សេវា មានន័យថាជាចំណាត់ការពង្រឹងការអនុវត្តច្បាប់ដែលក្រសួងបញ្ឈប់អាជ្ញាបណ្ណជាបណ្តោះអាសន្ន ដើម្បីការពារសុខភាព សុវត្ថិភាព ឬសុខុមាលភាពរបស់កុមារដែលបានចុះឈ្មោះ ឬសាធារណជន។ (WAC 110-300 - **https://app.leg.wa.gov/wac/default.aspx?cite=110-300&full=true**)

### សំណួរ៖ ហេតុអ្វីបានជាអ្នកផ្តល់សេវាថែទាំកុមារត្រូវគេព្យួរអាជ្ញាបណ្ណ?

**ចម្លើយ៖** តួនាទីមួយផ្នែករបស់ DCYF ក្នុងការធានាថាកុមារស្ថិតនៅក្នុងបរិយាកាសដែលផ្តល់សុខភាពល្អ និងមានសុវត្ថិភាព គឺពិចារណាអំពីការចោទប្រកាន់អំពីការបំពាន ឬការមិនយកចិត្តទុកដាក់លើកុមារព្រមទាំងហានិភ័យផ្នែកសុវត្ថិភាព និងសុខភាពដែលជិតកើតឡើងចំពោះកុមារ។

### សំណួរ៖ តើ DCYF អាចប្រាប់អ្វីខ្លះដល់ខ្ញុំអំពីការព្យួរអាជ្ញាបណ្ណ?

**ចម្លើយ៖** ការព្យួរអាជ្ញាបណ្ណទំនងជាផ្នែកមួយនៃការស៊ើបអង្កេតបណ្តឹងចំហ ដូច្នេះហើយ ប្រហែលជាគេមិនប្រាប់ព័ត៌មានច្រើនទេ។ អ្នកអាចរកទីតាំងការិយាល័យប្រចាំតំបន់របស់អ្នក បើសិនជាអ្នកមានសំណួរបន្ថែម៖
**https://dcyf.wa.gov/find-an-office/el-offices**

### សំណួរ៖ បើសិនជាខ្ញុំចង់មើលព័ត៌មានលម្អិតអំពីបណ្តឹង ឬការព្យួរអាជ្ញាបណ្ណនៅពេលដែលវាចប់សព្វគ្រប់ តើខ្ញុំអាចរកព័ត៌មាននោះនៅឯណា?

**ចម្លើយ៖** សម្រាប់ការលាតត្រដាងជាសាធារណ: និងសំណើបញ្ចេញកំណត់ត្រាទាំងអស់ សូមទាក់ទងផ្នែកកំណត់ត្រាសាធារណ:របស់យើងតាមរេបសាយ **https://dcyf.wa.gov/public-records**។ អ្នកក៏អាចរកព័ត៌មានខ្លះអំពី Child Care Check (ការពិនិត្យការថែទាំកុមារ) តាមវេបសាយ  បានផងដែរ។ **https://dcyf.wa.gov/services/earlylearning-childcare/child-care-check**

### សំណួរ៖ បើសិនជាខ្ញុំមានក្តីបារម្ភបន្ថែមអំពីសុខភាព និងសុវត្ថិភាពកូនរបស់ខ្ញុំនៅមណ្ឌលថែទាំកុមារ តើខ្ញុំអាចទូរសព្ទទៅអ្នកណា?

**ចម្លើយ៖** សូមហៅទៅខ្សែទូរសព្ទសាកសួរព័ត៌មាន 24/7 របស់ DCYF លេខ 1-866-363-4276 ឬលេខសាកសួរព័ត៌មានក្នុងមូលដ្ឋានរបស់អ្នក៖ **www.dcyf.wa.gov/safety/report-abuse**

### សំណួរ៖ តើខ្ញុំត្រូវធ្វើដូចម្តេចបើកូនរបស់ខ្ញុំទទួលឧបត្ថម្ភធនសម្រាប់ការថែទាំកុមារ?

**ចម្លើយ៖** សូមទាក់ទងមជ្ឈមណ្ឌលទំនាក់ទំនងឧបត្ថម្ភធនសម្រាប់ការថែទាំកុមារតាមលេខ 1-844-626-8687

### សំណួរ៖ តើខ្ញុំអាចរកសេវាថែទាំកុមារផ្សេងនៅឯណា?

**ចម្លើយ៖** នេះជាធនធានមួយចំនួនដើម្បីជួយឱ្យអ្នកស្វែងរកសេវាថែទាំកុមារដែលមានអាជ្ញាបណ្ណ៖

- Child Care Check (ការពិនិត្យការថែទាំកុមារ)
  **https://dcyf.wa.gov/services/earlylearningchildcare/child-care-check**
  1 (866) 482-4325, **ជម្រើសលេខ 3**
- Child Care Aware (បណ្តាញការយល់ដឹងអំពីការថែទាំកុមារ) នៃរដ្ឋ Washington
  **https://childcareawarewa.org**
  1 (800) 446-1114
  **familycenter@childcare.org**

*ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃឯកសារបោះពុម្ពនេះដោយឥតគិតថ្លៃជាទម្រង់ ឬភាសាផ្សេងទៀត សូមទាក់ទងផ្នែកទំនាក់ទំនងមណ្ឌល DCYF តាមរយ:លេខ 1-800-723-4831 ឬអ៊ីមែល communications@dcyf.wa.gov។*

DCYF PUBLICATION LIC_0077 CA (02-2025) Cambodian

Washington State Department of
CHILDREN, YOUTH & FAMILIES